តេលេក្រាម ឯកសារមន្ត្រីសាធារណៈ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ : ១០២ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ការផាកពិន័យចំពោះអំពើល្មើសនឹងច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤១៦/០០៦ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម
- បានឃើញអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញអនុក្រឹត្យលេខ១១៣ អនក្រ.បក ចុះថ្ងៃទី២ ខែសីហា ឆ្នាំ២០១៩ ស្តីពីការបង្កើត ការរៀបចំនិងការប្រព្រឹត្តទៅនៃស្ថាប័នវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់អំពីអំពើល្មើស និងប្រាក់ផាកពិន័យចំពោះអំពើល្មើសនឹងច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ព្រមទាំងកំណត់អំពីសមត្ថកិច្ច វិធានការ និងយន្តការនៃការផាកពិន័យនិងការគ្រប់គ្រងការផាកពិន័យ ដើម្បីធានាបាននូវប្រសិទ្ធភាពក្នុងការអនុវត្តច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម។

**មាត្រា២ .-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះ៖

- សហគ្រាសរងសវនកម្មនិងសហគ្រាសមិនរងសវនកម្ម ដែលបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម និង/ឬនៅអគ្គនាយកដ្ឋានពន្ធដារ និងដែលជាសហគ្រាសអ្នកជាប់ពន្ធធំនិងសហគ្រាសអ្នកជាប់ពន្ធមធ្យម និងគ្រប់អង្គភាពមិនស្វែងរកប្រាក់ចំណេញដែលបានចុះបញ្ជីនៅក្រសួង ស្ថាប័នមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា
- គ្រប់គណនេយ្យករនិងសវនករដែលជាសមាជិករបស់វិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា និងមានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យឬសវនកម្មពីនិយ័តករគណនេយ្យនិងសវនកម្ម (**ន.គ.ស.**)។

**មាត្រា៣ .-**

វាក្យសព្ទសំខាន់ៗដែលប្រើនៅក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

- **ការរាយការណ៍ព័ត៌មានហិរញ្ញវត្ថុប្រចាំឆ្នាំខុសដោយចេតនា** សំដៅដល់ការរាយការណ៍ដោយចេតនានូវព័ត៌មានហិរញ្ញវត្ថុដែលបង្ហាញរូបភាពមិនពិតនៃស្ថានភាពហិរញ្ញវត្ថុ ប្រតិបត្តិការ ឬប្រាក់ចំណេញរបស់ខ្លួនក្នុងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ
- **ការកាន់បញ្ជីគណនេយ្យមិនត្រឹមត្រូវ** សំដៅដល់ការកត់ត្រាប្រតិបត្តិការចំណូល ចំណាយ និងសាច់ប្រាក់មិនបានពេញលេញ ឬការកត់ត្រាប្រតិបត្តិការគណនេយ្យមិនមានឯកសារគាំទ្រត្រឹមត្រូវ។ ករណីនេះមិនអនុវត្តចំពោះគោលការណ៍គណនេយ្យដែលមានចែងក្នុងស្តង់ដាគណនេយ្យជាធរមានឡើយ
- **ការមិនកាន់បញ្ជីគណនេយ្យ** សំដៅដល់ការមិនបានរៀបចំឯកសារគណនេយ្យ ឬការមិនកត់ត្រាប្រតិបត្តិការទាំងនោះចូលទៅក្នុងសៀវភៅឬបញ្ជីគណនេយ្យ ដែលបានកំណត់ក្នុងច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- **ការមិនដាក់តម្កល់របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំមក ន.គ.ស.** សំដៅដល់ការដែលបុគ្គលជាប់កាតព្វកិច្ចខកខានក្នុងការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំមក **ន.គ.ស.** និងមិនបានស្នើសុំលេខអត្តសញ្ញាណកម្មរាយការណ៍ហិរញ្ញវត្ថុពី **ន.គ.ស.**
- **ការត្រួតពិនិត្យដល់ទីកន្លែង** សំដៅដល់ការត្រួតពិនិត្យដល់អាសយដ្ឋានគោលរបស់សហគ្រាស អង្គភាពមិនស្វែងរកប្រាក់ចំណេញ គណនេយ្យករ និងសវនករ

- **គណនេយ្យករឬសវនករជានីតិបុគ្គល** សំដៅដល់ក្រុមហ៊ុនគណនេយ្យឬក្រុមហ៊ុនសវនកម្មដែលទទួលបានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យឬអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្មពី **ន.គ.ស.**
- **គណនេយ្យករឬសវនករជារូបវន្តបុគ្គល** សំដៅដល់សមាជិកជារូបវន្តបុគ្គលរបស់វិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា ដែលទទួលបានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យឬអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្មពី **ន.គ.ស.**
- **បុគ្គលល្មើស** សំដៅដល់សហគ្រាស ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ ឬគណនេយ្យករ ឬសវនករដែលប្រព្រឹត្តល្មើសនឹងច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន
- **ម្ចាស់អាជ្ញាបណ្ណ** សំដៅដល់បុគ្គលដែលទទួលបានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យឬសវនកម្មពី **ន.គ.ស.**
- **របាយការណ៍ហិរញ្ញវត្ថុស្របតាមស្តង់ដាគណនេយ្យជាធរមាន** សំដៅដល់របាយការណ៍ហិរញ្ញវត្ថុដែលអនុលោមតាមលក្ខខណ្ឌចាំបាច់នានានៃស្តង់ដាគណនេយ្យលើការទទួលស្គាល់ ការឈប់ទទួលស្គាល់ ការវាស់វែង ការដាក់បង្ហាញ និងការលាតត្រដាងព័ត៌មាន ដែលបានអនុវត្តចំពោះប្រតិបត្តិការនិងព្រឹត្តិការណ៍
- **សហគ្រាសមិនរងសវនកម្ម**សំដៅដល់សហគ្រាសដែលមិនស្ថិតក្នុងលក្ខខណ្ឌត្រូវដាក់របាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនឱ្យរងសវនកម្មឯករាជ្យ
- **សហគ្រាសរងសវនកម្ម** សំដៅដល់សហគ្រាសដែលស្ថិតក្នុងលក្ខខណ្ឌត្រូវដាក់របាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនឱ្យរងសវនកម្មឯករាជ្យ ដែលលក្ខខណ្ឌនោះត្រូវកំណត់ដោយបទប្បញ្ញត្តិជាធរមាន
- **អង្គភាពមិនស្វែងរកប្រាក់ចំណេញមិនរងសវនកម្ម** សំដៅដល់អង្គភាពមិនស្វែងរកប្រាក់ចំណេញដែលមិនស្ថិតក្នុងលក្ខខណ្ឌត្រូវដាក់របាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនឱ្យរងសវនកម្មឯករាជ្យ
- **អង្គភាពមិនស្វែងរកប្រាក់ចំណេញរងសវនកម្ម** សំដៅដល់អង្គភាពមិនស្វែងរកប្រាក់ចំណេញដែលស្ថិតក្នុងលក្ខខណ្ឌត្រូវដាក់របាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនឱ្យរងសវនកម្មឯករាជ្យ ដែលលក្ខខណ្ឌនោះត្រូវកំណត់ដោយបទប្បញ្ញត្តិជាធរមាន
- **អំពើរាំងស្ទះ** សំដៅដល់ការប្រព្រឹត្តនូវអំពើណាមួយដោយបុគ្គលល្មើស រួមមាន៖
  - ១- ពុំបានផ្តល់កិច្ចសហការជាមួយមន្ត្រីនៃ **ន.គ.ស.** ដែលកំពុងអនុវត្តភារកិច្ច ឬ
  - ២- មិនអនុញ្ញាតឱ្យ **ន.គ.ស.** ធ្វើការពិនិត្យបញ្ជីគណនេយ្យឬឯកសារគណនេយ្យផ្សេងៗ ឬ
  - ៣- កសាងឬផ្តល់នូវកំណត់ត្រា ឯកសារ របាយការណ៍ ឬព័ត៌មានមិនត្រឹមត្រូវពាក់ព័ន្ធគណនេយ្យ ឬ
  - ៤- មិនបានជូនដំណឹងទៅ **ន.គ.ស.** អំពីការផ្លាស់ប្តូរព័ត៌មានរបស់សហគ្រាសនិងអង្គភាពមិនស្វែងរកប្រាក់ចំណេញ។

## ជំពូកទី២
## ស្ថាប័នមានសមត្ថកិច្ច

**មាត្រា៤ .-**

ការអនុវត្តការផាកពិន័យចំពោះអំពើល្មើសនឹងច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម ជាសមត្ថកិច្ចរបស់ **ន.គ.ស.**។

**ន.គ.ស.** អាចដាក់ចេញវិធានការពាក់ព័ន្ធផ្សេងទៀត អនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ពាក់ព័ន្ធជាធរមាន។

**មាត្រា៥ .-**

អគ្គនាយកនៃ **ន.គ.ស.** មានសមត្ថកិច្ចចាត់ចែងការត្រួតពិនិត្យការអនុវត្តកាតព្វកិច្ចគណនេយ្យ និងសវនកម្ម អនុលោមតាមច្បាប់ស្តីពីគណនេយ្យនិងសវនកម្មនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

## ជំពូកទី៣
## អំពើល្មើសនិងប្រាក់ផាកពិន័យ

**មាត្រា៦ .-**

សហគ្រាសរងសវនកម្ម ត្រូវទទួលរងការផាកពិន័យជាប្រាក់ចំពោះអំពើល្មើសមួយឬច្រើន ដូចខាងក្រោម៖

១- ការមិនដាក់តម្កល់របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំមក **ន.គ.ស.** ត្រូវទទួលរងការផាកពិន័យ ជាប្រាក់៦០ ០០០ ០០០(ហុកសិបលាន)រៀល។

២- ការមិនដាក់របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំឱ្យរងសវនកម្មឯករាជ្យ តាមលក្ខខណ្ឌកំណត់ដោយ បទប្បញ្ញត្តិជាធរមាន ត្រូវទទួលរងការផាកពិន័យជាប្រាក់២០ ០០០ ០០០(ម្ភៃលាន)រៀល។

៣- ការមិនកាន់បញ្ជីគណនេយ្យ ត្រូវទទួលរងការផាកពិន័យជាប្រាក់១០ ០០០ ០០០(ដប់លាន) រៀល។

៤- ការកាន់បញ្ជីគណនេយ្យមិនត្រឹមត្រូវ ត្រូវទទួលរងការផាកពិន័យជាប្រាក់៥ ០០០ ០០០(ប្រាំលាន) រៀល។

៥- ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំមិនស្របតាមស្តង់ដាគណនេយ្យជាធរមាន ត្រូវទទួល រងការផាកពិន័យជាប្រាក់១០ ០០០ ០០០(ដប់លាន)រៀល។

៦- ការមិនប្រើរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ការបំពេញកាតព្វកិច្ចសារពើពន្ធ ត្រូវទទួលរងការ ផាកពិន័យជាប្រាក់១០ ០០០ ០០០(ដប់លាន)រៀល។

៧- ការមិនរក្សាទុកឯកសារគណនេយ្យស្របតាមពេលវេលាកំណត់ដោយច្បាប់ ត្រូវទទួលរងការ ផាកពិន័យជាប្រាក់១០ ០០០ ០០០(ដប់លាន)រៀល។

៨- ការប្រព្រឹត្តអំពើរាំងស្ទះដល់ការអនុវត្តបទប្បញ្ញត្តិគណនេយ្យនិងសវនកម្ម ត្រូវទទួលរងការ ផាកពិន័យជាប្រាក់១០ ០០០ ០០០(ដប់លាន)រៀល។

៩- ការរាយការណ៍ព័ត៌មានហិរញ្ញវត្ថុប្រចាំឆ្នាំខុសដោយចេតនា ត្រូវទទួលរងការផាកពិន័យជាប្រាក់ ១០ ០០០ ០០០(ដប់លាន)រៀល។

១០- ការមិនប្រើប្រាក់រៀលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ សម្រាប់ដាក់តម្កល់នៅ **ន.គ.ស.** ត្រូវទទួលរងការផាកពិន័យជាប្រាក់២ ០០០ ០០០(ពីរលាន)រៀល។

១១- ការមិនប្រើភាសាខ្មែរនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ សម្រាប់ដាក់តម្កល់នៅ **ន.គ.ស.** ត្រូវ ទទួលរងការផាកពិន័យជាប្រាក់២ ០០០ ០០០(ពីរលាន)រៀល។

១២- ការប្រើការិយបរិច្ឆេទគណនេយ្យខុសពីការកំណត់នៅក្នុងច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម ដោយគ្មានការអនុញ្ញាតជាមុនពី **ន.គ.ស.** ត្រូវទទួលរងការផាកពិន័យជាប្រាក់២ ០០០ ០០០ (ពីរលាន)រៀល។

**មាត្រា៧ .-**

សហគ្រាសមិនរងសវនកម្ម ត្រូវទទួលរងការផាកពិន័យជាប្រាក់ចំពោះអំពើល្មើសមួយឬច្រើនដូចខាងក្រោម៖

១- ការមិនដាក់តម្កល់របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំមក **ន.គ.ស.** ត្រូវទទួលរងការផាកពិន័យជាប្រាក់៥០ ០០០ ០០០(ហាសិបលាន)រៀល។

២- ការមិនកាន់បញ្ជីគណនេយ្យ ត្រូវទទួលរងការផាកពិន័យជាប្រាក់១០ ០០០ ០០០(ដប់លាន)រៀល។

៣- ការកាន់បញ្ជីគណនេយ្យមិនត្រឹមត្រូវ ត្រូវទទួលរងការផាកពិន័យជាប្រាក់៥ ០០០ ០០០(ប្រាំលាន)រៀល។

៤- ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំមិនស្របតាមស្តង់ដាគណនេយ្យជាធរមាន ត្រូវទទួលរងការផាកពិន័យជាប្រាក់៨ ០០០ ០០០(ប្រាំបីលាន)រៀល។

៥- ការមិនប្រើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំសម្រាប់ការបំពេញកាតព្វកិច្ចសារពើពន្ធ ត្រូវទទួលរងការផាកពិន័យជាប្រាក់៨ ០០០ ០០០(ប្រាំបីលាន)រៀល។

៦- ការមិនរក្សាទុកឯកសារគណនេយ្យស្របតាមពេលវេលាកំណត់ដោយច្បាប់ ត្រូវទទួលរងការផាកពិន័យជាប្រាក់១០ ០០០ ០០០(ដប់លាន)រៀល។

៧- ការប្រព្រឹត្តអំពើរាំងស្ទះដល់ការអនុវត្តបទប្បញ្ញត្តិគណនេយ្យនិងសវនកម្ម ត្រូវទទួលរងការផាកពិន័យជាប្រាក់១០ ០០០ ០០០(ដប់លាន)រៀល។

៨- ការរាយការណ៍ព័ត៌មានហិរញ្ញវត្ថុប្រចាំឆ្នាំខុសដោយចេតនា ត្រូវទទួលរងការផាកពិន័យជាប្រាក់១០ ០០០ ០០០(ដប់លាន)រៀល។

៩- ការមិនប្រើប្រាក់រៀលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ សម្រាប់ដាក់តម្កល់នៅ **ន.គ.ស.** ត្រូវទទួលរងការផាកពិន័យជាប្រាក់២ ០០០ ០០០(ពីរលាន)រៀល។

១០- ការមិនប្រើភាសាខ្មែរនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ សម្រាប់ដាក់តម្កល់នៅ **ន.គ.ស.** ត្រូវទទួលរងការផាកពិន័យជាប្រាក់២ ០០០ ០០០(ពីរលាន)រៀល។

១១- ការប្រើការិយបរិច្ឆេទគណនេយ្យខុសពីការកំណត់នៅក្នុងច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម ដោយគ្មានការអនុញ្ញាតជាមុនពី **ន.គ.ស.** ត្រូវទទួលរងការផាកពិន័យជាប្រាក់២ ០០០ ០០០(ពីរលាន)រៀល។

**មាត្រា៨ .-**

អង្គភាពមិនស្វែងរកប្រាក់ចំណេញរងសវនកម្ម ត្រូវទទួលរងការផាកពិន័យជាប្រាក់ចំពោះអំពើល្មើសមួយឬច្រើនដូចខាងក្រោម៖

១- ការមិនដាក់តម្កល់របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំនៅ **ន.គ.ស.** ត្រូវទទួលរងការផាកពិន័យជាប្រាក់៣៦ ០០០ ០០០(សាមសិបប្រាំមួយលាន)រៀល។

២- ការមិនដាក់របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំឱ្យរងសវនកម្មឯករាជ្យ តាមលក្ខខណ្ឌដែលកំណត់ដោយបទប្បញ្ញត្តិជាធរមាន ត្រូវទទួលរងការផាកពិន័យជាប្រាក់១ ៦០០ ០០០(មួយលានប្រាំមួយសែន)រៀល។

៣- ការមិនកាន់បញ្ជីគណនេយ្យ ត្រូវទទួលរងការផាកពិន័យជាប្រាក់៦ ៤០០ ០០០(ប្រាំមួយលានបួនសែន)រៀល។
៤- ការកាន់បញ្ជីគណនេយ្យមិនត្រឹមត្រូវ ត្រូវទទួលរងការផាកពិន័យជាប្រាក់៣ ២០០ ០០០ (បីលានពីរសែន)រៀល។
៥- ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំមិនស្របតាមស្តង់ដាគណនេយ្យជាធរមាន ត្រូវទទួលរងការផាកពិន័យជាប្រាក់៦ ០០០ ០០០(ប្រាំមួយលាន)រៀល។
៦- ការមិនប្រើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំសម្រាប់ការបំពេញកាតព្វកិច្ចសារពើពន្ធ ត្រូវទទួលរងការផាកពិន័យជាប្រាក់៤ ៨០០ ០០០(បួនលានប្រាំបីសែន)រៀល។
៧- ការមិនរក្សាទុកឯកសារគណនេយ្យស្របតាមពេលវេលាកំណត់ដោយច្បាប់ ត្រូវទទួលរងការផាកពិន័យជាប្រាក់៨ ០០០ ០០០(ប្រាំបីលាន)រៀល។
៨- ការប្រព្រឹត្តអំពើរាំងស្ទះដល់ការអនុវត្តបទប្បញ្ញត្តិគណនេយ្យនិងសវនកម្ម ត្រូវទទួលរងការផាកពិន័យជាប្រាក់៦ ០០០ ០០០(ប្រាំមួយលាន)រៀល។
៩- ការរាយការណ៍ព័ត៌មានហិរញ្ញវត្ថុប្រចាំឆ្នាំខុសដោយចេតនា ត្រូវទទួលរងការផាកពិន័យជាប្រាក់៨ ០០០ ០០០(ប្រាំបីលាន)រៀល។
១០- ការមិនប្រើប្រាក់រៀលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ សម្រាប់ដាក់តម្កល់នៅ **ន.គ.ស**. ត្រូវទទួលរងការផាកពិន័យជាប្រាក់២ ០០០ ០០០(ពីរលាន)រៀល។
១១- ការមិនប្រើភាសាខ្មែរនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ សម្រាប់ដាក់តម្កល់នៅ **ន.គ.ស**. ត្រូវទទួលរងការផាកពិន័យជាប្រាក់២ ០០០ ០០០(ពីរលាន)រៀល។
១២- ការប្រើវាក្យសព្ទបរិច្ឆេទគណនេយ្យខុសពីការកំណត់នៅក្នុងច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម ដោយគ្មានការអនុញ្ញាតជាមុនពី **ន.គ.ស**. ត្រូវទទួលរងការផាកពិន័យជាប្រាក់២ ០០០ ០០០ (ពីរលាន)រៀល។

**មាត្រា៩ .-**

អង្គភាពមិនស្វែងរកប្រាក់ចំណេញមិនរងសវនកម្ម ត្រូវទទួលរងការផាកពិន័យជាប្រាក់ចំពោះអំពើល្មើសមួយឬច្រើនដូចខាងក្រោម៖

១- ការមិនដាក់តម្កល់របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំនៅ **ន.គ.ស.** ត្រូវទទួលរងការផាកពិន័យជាប្រាក់២៧ ០០០ ០០០(ម្ភៃប្រាំពីរលាន)រៀល។
២- ការមិនកាន់បញ្ជីគណនេយ្យ ត្រូវទទួលរងការផាកពិន័យជាប្រាក់៥ ០០០ ០០០(ប្រាំលាន) រៀល។
៣- ការកាន់បញ្ជីគណនេយ្យមិនត្រឹមត្រូវ ត្រូវទទួលរងការផាកពិន័យជាប្រាក់២ ៥០០ ០០០ (ពីរលានប្រាំសែន)រៀល។
៤- ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំមិនស្របតាមស្តង់ដាគណនេយ្យជាធរមាន ត្រូវទទួលរងការផាកពិន័យជាប្រាក់៥ ០០០ ០០០(ប្រាំលាន)រៀល។
៥- ការមិនប្រើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំសម្រាប់ការបំពេញកាតព្វកិច្ចសារពើពន្ធ ត្រូវទទួលរងការផាកពិន័យជាប្រាក់៤ ០០០ ០០០(បួនលាន)រៀល។

៦- ការមិនរក្សាទុកឯកសារគណនេយ្យស្របតាមពេលវេលាកំណត់ដោយច្បាប់ ត្រូវទទួលរងការផាកពិន័យជាប្រាក់៦ ០០០ ០០០(ប្រាំមួយលាន)រៀល។

៧- ការប្រព្រឹត្តអំពើរាំងស្ទះដល់ការអនុវត្តបទប្បញ្ញត្តិគណនេយ្យនិងសវនកម្ម ត្រូវទទួលរងការផាកពិន័យជាប្រាក់៣ ០០០ ០០០(បីលាន)រៀល។

៨- ការរាយការណ៍ព័ត៌មានហិរញ្ញវត្ថុប្រចាំឆ្នាំខុសដោយចេតនា ត្រូវទទួលរងការផាកពិន័យជាប្រាក់៦ ០០០ ០០០(ប្រាំមួយលាន)រៀល។

៩- ការមិនប្រើប្រាក់រៀលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ សម្រាប់ដាក់តម្កល់នៅ **ន.គ.ស.** ត្រូវទទួលរងការផាកពិន័យជាប្រាក់២ ០០០ ០០០(ពីរលាន)រៀល។

១០- ការមិនប្រើភាសាខ្មែរនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ សម្រាប់ដាក់តម្កល់នៅ **ន.គ.ស.** ត្រូវទទួលរងការផាកពិន័យជាប្រាក់២ ០០០ ០០០(ពីរលាន)រៀល។

១១- ការប្រើការិយបរិច្ឆេទគណនេយ្យខុសពីការកំណត់នៅក្នុងច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម ដោយគ្មានការអនុញ្ញាតជាមុនពី **ន.គ.ស.** ត្រូវទទួលរងការផាកពិន័យជាប្រាក់២ ០០០ ០០០ (ពីរលាន)រៀល។

**មាត្រា១០ .-**

គណនេយ្យករជារូបវន្តបុគ្គល ត្រូវទទួលរងការផាកពិន័យជាប្រាក់ចំពោះអំពើល្មើសមួយឬច្រើនដូចខាងក្រោម៖

១- ការប្រព្រឹត្តល្មើសនឹងកថាខណ្ឌទី២ នៃមាត្រា២៨ នៃច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម ត្រូវទទួលរងការផាកពិន័យជាប្រាក់៥ ០០០ ០០០(ប្រាំលាន)រៀល។

២- ការយឺតយ៉ាវក្នុងការបង់កម្រៃអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យប្រចាំឆ្នាំ តាមពេលកំណត់ក្នុងបទប្បញ្ញត្តិជាធរមាន ម្ចាស់អាជ្ញាបណ្ណត្រូវទទួលរងការផាកពិន័យ១០០ ០០០(មួយសែន)រៀល ក្នុងមួយថ្ងៃ។

៣- ការយឺតយ៉ាវក្នុងការដាក់ពាក្យស្នើសុំបន្តអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យ តាមពេលកំណត់ក្នុងបទប្បញ្ញត្តិជាធរមាន ត្រូវទទួលរងការផាកពិន័យ១០០ ០០០(មួយសែន)រៀល ក្នុងមួយថ្ងៃ។

៤- ការមានវត្តមានរបស់គណនេយ្យករជាជនបរទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា តិចជាងរយៈពេលដូចមានកំណត់ក្នុងបទប្បញ្ញត្តិជាធរមាន ត្រូវទទួលរងការផាកពិន័យ២០០ ០០០ (ពីរសែន)រៀលក្នុងមួយថ្ងៃ។

**មាត្រា១១ .-**

សវនករជារូបវន្តបុគ្គល ត្រូវទទួលរងការផាកពិន័យជាប្រាក់ចំពោះអំពើល្មើសមួយឬច្រើនដូចខាងក្រោម៖

១- ការប្រព្រឹត្តល្មើសនឹងកថាខណ្ឌទី២ នៃមាត្រា២៨ នៃច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម ត្រូវទទួលរងការផាកពិន័យជាប្រាក់២០ ០០០ ០០០(ម្ភៃលាន)រៀល។

២- ការយឺតយ៉ាវក្នុងការបង់កម្រៃអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្មប្រចាំឆ្នាំ តាមពេលកំណត់ក្នុងបទប្បញ្ញត្តិជាធរមាន ត្រូវទទួលរងការផាកពិន័យ១៥០ ០០០(មួយសែនប្រាំម៉ឺន)រៀល ក្នុងមួយថ្ងៃ។

៣- ការយឺតយ៉ាវក្នុងការដាក់ពាក្យស្នើសុំបន្តអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្ម តាមពេលកំណត់ក្នុងបទប្បញ្ញត្តិជាធរមាន ត្រូវទទួលរងការផាកពិន័យ១៥០ ០០០(មួយសែនប្រាំម៉ឺន)រៀល ក្នុងមួយថ្ងៃ។

៤- ការមានវត្តមានរបស់សវនករជាជនបរទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា តិចជាងរយៈពេលដូចមានកំណត់ក្នុងបទប្បញ្ញត្តិជាធរមាន ត្រូវទទួលរងការផាកពិន័យ៤០០ ០០០(បួនសែន) រៀលក្នុងមួយថ្ងៃ។

៥- ការមិនចារឹកឈ្មោះនិងហត្ថលេខារបស់សវនករជារូបវន្តបុគ្គលលើរបាយការណ៍សវនកម្មឯករាជ្យ ត្រូវទទួលរងការផាកពិន័យ១០ ០០០ ០០០(ដប់លាន)រៀល ក្នុងមួយរបាយការណ៍។

៦- ការរៀបចំរបាយការណ៍សវនកម្មដោយមិនប្រើភាសាខ្មែរ ឬប្រើភាសាដទៃដោយគ្មានការអនុញ្ញាត ត្រូវទទួលរងការផាកពិន័យ១០ ០០០ ០០០(ដប់លាន)រៀល។

៧- ការរៀបចំរបាយការណ៍សវនកម្មមិនស្របតាមស្តង់ដាសវនកម្ម និងការអះអាងអន្តរជាតិនៃកម្ពុជា ត្រូវទទួលរងការផាកពិន័យ១០ ០០០ ០០០(ដប់លាន)រៀល។

៨- ការផ្តល់សេវាសវនកម្មជូនសហគ្រាសឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ ដោយមិនស្របតាមលក្ខខណ្ឌដែលកំណត់ក្នុងកថាខណ្ឌទី១ នៃមាត្រា១៥ នៃច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម ត្រូវទទួលរងការផាកពិន័យ២០ ០០០ ០០០(ម្ភៃលាន)រៀល។

៩- ការផ្តល់សេវាសវនកម្មជូនសហគ្រាសឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ ដោយមិនស្របតាមលក្ខខណ្ឌដែលកំណត់ក្នុងកថាខណ្ឌទី២ នៃមាត្រា១៥ នៃច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម ត្រូវទទួលរងការផាកពិន័យ២០ ០០០ ០០០(ម្ភៃលាន)រៀល។

១០- ការមិនរក្សាទុកភស្តុតាងសវនកម្មក្នុងរយៈពេលដប់ឆ្នាំយ៉ាងតិច ចាប់ពីកាលបរិច្ឆេទចេញរបាយការណ៍សវនកម្ម ត្រូវទទួលរងការផាកពិន័យ២០ ០០០ ០០០(ម្ភៃលាន)រៀល។

**មាត្រា១២ .-**

គណនេយ្យករជានីតិបុគ្គល ត្រូវទទួលរងការផាកពិន័យជាប្រាក់ចំពោះអំពើល្មើសមួយឬច្រើនដូចខាងក្រោម៖

១- ការយឺតយ៉ាវក្នុងការបង់កម្រៃអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យប្រចាំឆ្នាំ តាមពេលកំណត់ក្នុងបទប្បញ្ញត្តិជាធរមាន ម្ចាស់អាជ្ញាបណ្ណត្រូវទទួលរងការផាកពិន័យ១៥០ ០០០(មួយសែនប្រាំម៉ឺន)រៀល ក្នុងមួយថ្ងៃ។

២- ការយឺតយ៉ាវក្នុងការដាក់ពាក្យស្នើសុំបន្តអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យ តាមពេលកំណត់ក្នុងបទប្បញ្ញត្តិជាធរមាន ត្រូវទទួលរងការផាកពិន័យ១៥០ ០០០(មួយសែនប្រាំម៉ឺន)រៀល ក្នុងមួយថ្ងៃ។

៣- ការយឺតយ៉ាវក្នុងការផ្តល់របាយការណ៍អំពីបុគ្គលិកមក **ន.គ.ស**. តាមពេលកំណត់ក្នុងបទប្បញ្ញត្តិជាធរមាន ត្រូវទទួលរងការផាកពិន័យ១០០ ០០០(មួយសែន)រៀល ក្នុងមួយថ្ងៃ។

៤- ការយឺតយ៉ាវក្នុងការផ្តល់របាយការណ៍ស្ថិតិលម្អិតនៃអតិថិជន និងរបាយការណ៍ផ្សេងទៀតប្រចាំឆមាសនិងប្រចាំឆ្នាំមក **ន.គ.ស**. តាមពេលកំណត់ក្នុងបទប្បញ្ញត្តិជាធរមាន តាមទម្រង់និងសេចក្តីណែនាំរបស់ **ន.គ.ស**. ត្រូវទទួលរងការផាកពិន័យ១០០ ០០០(មួយសែន)រៀល ក្នុងមួយថ្ងៃ។

៥- ការយឺតយ៉ាវក្នុងការជូនដំណឹងមក **ន.គ.ស**. តាមពេលកំណត់ក្នុងបទប្បញ្ញត្តិជាធរមាន ក្រោយពីមានការផ្លាស់ប្តូរលក្ខន្តិកៈក្រុមហ៊ុន អាសយដ្ឋាន លេខទូរសព្ទ អ៊ីមែល ត្រូវទទួលរងការផាកពិន័យ១០០ ០០០(មួយសែន)រៀល ក្នុងមួយថ្ងៃ។

៦- ការមិនបានសុំគោលការណ៍អនុញ្ញាតជាមុនពី **ន.គ.ស**. លើការផ្លាស់ប្តូរព័ត៌មានក្រុមហ៊ុន ដែលប៉ះពាល់ដល់នីតិសម្បទានៃការប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម ត្រូវទទួលរងការផាកពិន័យ១០០ ០០០(មួយសែន)រៀល ក្នុងមួយថ្ងៃ។

៧- ការមិនរក្សាទុកនូវបញ្ជីគណនេយ្យនិងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់សហគ្រាសជាអតិថិជនសេវាជម្រះបញ្ជីដែលរំលាយស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន ត្រូវទទួលរងការផាកពិន័យ១០០ ០០០(មួយសែន)រៀល ក្នុងមួយថ្ងៃ។

៨- ការមិនបានអនុវត្តផែនការបណ្តុះបណ្តាលបុគ្គលិកខ្មែរស្របតាមផែនការដាក់មក **ន.គ.ស**. ត្រូវទទួលរងការផាកពិន័យ៥ ០០០ ០០០(ប្រាំលាន)រៀល។

៩- ការមិនរាយការណ៍ជូនស្ថាប័នមានសមត្ថកិច្ច ក្នុងករណីរកឃើញប្រតិបត្តិការសង្ស័យពាក់ព័ន្ធការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ត្រូវទទួលរងការផាកពិន័យ២០ ០០០ ០០០(ម្ភៃលាន)រៀល ក្នុងមួយករណី។

**មាត្រា១៣ .-**

សវនករជានីតិបុគ្គល ត្រូវទទួលរងការផាកពិន័យជាប្រាក់ចំពោះអំពើល្មើសមួយឬច្រើនដូចខាងក្រោម៖

១- ការផ្តល់សេវាជម្រះបញ្ជីដោយមិនបានបំពេញលក្ខខណ្ឌអនុលោមតាមបទប្បញ្ញត្តិជាធរមាន ត្រូវទទួលរងការផាកពិន័យជាប្រាក់១០ ០០០ ០០០(ដប់លាន)រៀល។

២- ការផ្តល់សេវាសវនកម្មជូនសហគ្រាសឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ ដោយមិនស្របតាមលក្ខខណ្ឌដែលកំណត់ក្នុងកថាខណ្ឌទី១ នៃមាត្រា១៥ នៃច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម ត្រូវទទួលរងការផាកពិន័យជាប្រាក់២០ ០០០ ០០០(ម្ភៃលាន)រៀល។

៣- ការមិនប្តូរវេនសវនករជារូបវន្តបុគ្គលលើសពីរយៈពេល៥(ប្រាំ)ឆ្នាំបន្តបន្ទាប់គ្នា ត្រូវទទួលរងការផាកពិន័យជាប្រាក់២០ ០០០ ០០០(ម្ភៃលាន)រៀល។

៤- ការផ្តល់សេវាសវនកម្មជូនសហគ្រាសឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ ដោយមិនស្របតាមលក្ខខណ្ឌដែលកំណត់ក្នុងកថាខណ្ឌទី៣ នៃមាត្រា១៥ នៃច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម ត្រូវទទួលរងការផាកពិន័យជាប្រាក់៣០ ០០០ ០០០(សាមសិបលាន)រៀល។

៥- ការយឺតយ៉ាវក្នុងការបង់កម្រៃអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្មប្រចាំឆ្នាំ តាមពេលកំណត់ក្នុងបទប្បញ្ញត្តិជាធរមាន ម្ចាស់អាជ្ញាបណ្ណត្រូវទទួលរងការផាកពិន័យ២០០ ០០០(ពីរសែន) រៀល ក្នុងមួយថ្ងៃ។

៦- ការយឺតយ៉ាវក្នុងការដាក់ពាក្យស្នើសុំបន្តអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្ម តាមពេលកំណត់ក្នុងបទប្បញ្ញត្តិជាធរមាន ត្រូវទទួលរងការផាកពិន័យ២០០ ០០០(ពីរសែន)រៀល ក្នុងមួយថ្ងៃ។

៧- ការយឺតយ៉ាវក្នុងការផ្តល់របាយការណ៍អំពីបុគ្គលិកមក **ន.គ.ស**. តាមពេលកំណត់ក្នុងបទប្បញ្ញត្តិជាធរមាន ត្រូវទទួលរងការផាកពិន័យ១០០ ០០០(មួយសែន)រៀល ក្នុងមួយថ្ងៃ។

៨- ការយឺតយ៉ាវក្នុងការផ្តល់របាយការណ៍ស្ថិតិលម្អិតនៃអតិថិជនប្រចាំឆមាសនិងប្រចាំឆ្នាំមក **ន.គ.ស**. តាមពេលកំណត់ក្នុងបទប្បញ្ញត្តិជាធរមាន ត្រូវទទួលរងការផាកពិន័យ១០០ ០០០ (មួយសែន)រៀល ក្នុងមួយថ្ងៃ។

៩- ការយឺតយ៉ាវក្នុងការជូនដំណឹងមក **ន.គ.ស**. តាមពេលកំណត់ក្នុងបទប្បញ្ញត្តិជាធរមាន ក្រោយពីមានការផ្លាស់ប្តូរលក្ខន្តិកៈក្រុមហ៊ុន អាសយដ្ឋាន លេខទូរសព្ទ អ៊ីមែល ត្រូវទទួលរងការផាកពិន័យ១០០ ០០០(មួយសែន)រៀល ក្នុងមួយថ្ងៃ។

១០- ការយឺតយ៉ាវក្នុងផ្តល់របាយការណ៍តម្លាភាពប្រចាំឆ្នាំ ចំពោះសហគ្រាសទទួលខុសត្រូវជាសាធារណៈដាក់មក **ន.គ.ស**. តាមពេលកំណត់ក្នុងបទប្បញ្ញត្តិជាធរមាន ត្រូវទទួលរងការផាកពិន័យ១០០ ០០០(មួយសែន)រៀល ក្នុងមួយថ្ងៃ។

១១- ការយឺតយ៉ាវក្នុងការផ្តល់របាយការណ៍ស្តីពីលទ្ធផលនៃការអនុវត្តផែនការបណ្តុះបណ្តាលប្រចាំឆ្នាំមក **ន.គ.ស**. តាមពេលកំណត់ក្នុងបទប្បញ្ញត្តិជាធរមាន ត្រូវទទួលរងការផាកពិន័យ ៥ ០០០ ០០០(ប្រាំលាន)រៀល។

១២- ការមិនបានសុំគោលការណ៍អនុញ្ញាតជាមុនពី **ន.គ.ស**. លើការផ្លាស់ប្តូរព័ត៌មានក្រុមហ៊ុនដែលប៉ះពាល់ដល់នីតិសម្បទានៃការប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម ត្រូវទទួលរងការផាកពិន័យ១ ០០០ ០០០(មួយលាន)រៀល។

១៣- ការមិនរក្សាទុកនូវបញ្ជីគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់សហគ្រាសជាអតិថិជនសេវាជម្រះបញ្ជីដែលរំលោភស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន ត្រូវទទួលរងការផាកពិន័យ១០ ០០០ ០០០(ដប់លាន)រៀល។

១៤- ការមិនបានអនុវត្តផែនការបណ្តុះបណ្តាលបុគ្គលិកខ្មែរ ស្របតាមផែនការដាក់បញ្ជូនមក **ន.គ.ស**. ត្រូវទទួលរងការផាកពិន័យ៥ ០០០ ០០០(ប្រាំលាន)រៀល។

១៥- ការផ្តល់សេវាសវនកម្មដោយគ្មានធានារ៉ាប់រងវិជ្ជាជីវៈ ឬធានារ៉ាប់រងផុតសុពលភាព ត្រូវទទួលរងការផាកពិន័យ១០ ០០០ ០០០(ដប់លាន)រៀល។

១៦- ការមិនរាយការណ៍ជូនស្ថាប័នមានសមត្ថកិច្ចក្នុងករណីរកឃើញប្រតិបត្តិការសង្ស័យពាក់ព័ន្ធការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ត្រូវទទួលរងការផាកពិន័យ២០ ០០០ ០០០(ម្ភៃលាន)រៀល។

## ជំពូកទី៤
## ការអនុវត្តការផាកពិន័យនិងយន្តការត្រួតពិនិត្យការអនុវត្តភាតព្វកិច្ច
### ផ្នែកទី១
### ការអនុវត្តការផាកពិន័យ

**មាត្រា១៤ ._**

ការផាកពិន័យចំពោះសហគ្រាសនិងអង្គភាពមិនស្វែងរកប្រាក់ចំណេញ ត្រូវអនុវត្តដូចខាងក្រោម៖

១- ការផាកពិន័យតាមរយៈការត្រួតពិនិត្យចំពោះសហគ្រាសនិងអង្គភាពមិនស្វែងរកប្រាក់ចំណេញដែលបានដាក់តម្កល់របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំនៅ **ន.គ.ស**.៖

១.១- ករណីរកឃើញអំពើល្មើសក្នុងការត្រួតពិនិត្យលើកទី១ អាចផ្តល់ការអនុគ្រោះលើការពិន័យចំពោះអំពើល្មើសនីមួយៗ ហើយ **ន.គ.ស.** អាចផ្តល់លិខិតក្រើនរំលឹកដើម្បីកែតម្រូវ ដោយផ្តល់ការណែនាំឬពន្យល់អំពីចំណុចដែលត្រឹមត្រូវ ឬអាចផាកពិន័យ ២០%(ម្ភៃភាគរយ) នៃប្រាក់ពិន័យចំពោះអំពើល្មើសនីមួយៗ។

១.២- ករណីរកឃើញអំពើល្មើសដដែលកើតមាននៅក្នុងការត្រួតពិនិត្យលើកទី២ ត្រូវបានផាកពិន័យ៤០%(សែសិបភាគរយ) នៃប្រាក់ពិន័យចំពោះអំពើល្មើសនីមួយៗ។

១.៣- ករណីរកឃើញអំពើល្មើសដដែលកើតមាននៅក្នុងការត្រួតពិនិត្យលើកទី៣ ត្រូវបានផាកពិន័យ៨០%(ប៉ែតសិបភាគរយ) នៃប្រាក់ពិន័យចំពោះអំពើល្មើសនីមួយៗ។

១.៤- ករណីរកឃើញអំពើល្មើសដដែលកើតមាននៅក្នុងការត្រួតពិនិត្យលើកទី៤ ត្រូវបានផាកពិន័យ១០០%(មួយរយភាគរយ) នៃប្រាក់ពិន័យចំពោះអំពើល្មើសនីមួយៗ។

២- ការផាកពិន័យតាមរយៈការត្រួតពិនិត្យចំពោះសហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញដែលមិនបានដាក់តម្កល់របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំនៅ **ន.គ.ស.៖**

២.១- ករណីរកឃើញអំពើល្មើសនៅក្នុងការត្រួតពិនិត្យលើកទី១ ត្រូវបានផាកពិន័យ៣០% (សាមសិបភាគរយ) នៃប្រាក់ពិន័យចំពោះអំពើល្មើសនីមួយៗ។ ហើយ **ន.គ.ស.** ត្រូវផ្តល់ការណែនាំឬពន្យល់អំពីចំណុចដែលត្រឹមត្រូវ។

២.២- ករណីរកឃើញអំពើល្មើសដដែលកើតមាននៅក្នុងការត្រួតពិនិត្យលើកទី២ ត្រូវបានផាកពិន័យ៥០%(ហាសិបភាគរយ) នៃប្រាក់ពិន័យចំពោះអំពើល្មើសនីមួយៗ។

២.៣- ករណីរកឃើញអំពើល្មើសដដែលកើតមាននៅក្នុងការត្រួតពិនិត្យលើកទី៣ ត្រូវបានផាកពិន័យ១០០%(មួយរយភាគរយ) នៃប្រាក់ពិន័យចំពោះអំពើល្មើសនីមួយៗ។

ការត្រួតពិនិត្យអនុលោមភាពរបស់សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញដូចបានកំណត់នៅក្នុងកថាខណ្ឌខាងលើនេះ ធ្វើឡើងមិនលើសពីមួយដងក្នុងមួយឆ្នាំ។

### មាត្រា១៥ .-

ការផាកពិន័យចំពោះគណនេយ្យករនិងសវនករ ដូចមានចែងក្នុងមាត្រា១០ ដល់មាត្រា១៣ នៃអនុក្រឹត្យនេះ ត្រូវធ្វើឡើងដោយឆ្លងកាត់ការត្រួតពិនិត្យដល់ទីកន្លែង ឬតាមរយៈមធ្យោបាយដាក់លាក់ផ្សេងទៀតជាយថាហេតុ។

### មាត្រា១៦ .-

មន្ត្រីមានសមត្ថកិច្ចរបស់ **ន.គ.ស.** ដែលមិនបានបំពេញតួនាទីរបស់ខ្លួនដោយភាពស្មោះត្រង់ ឬមិនគោរពបទបញ្ជាផ្ទៃក្នុង និងក្រមសីលធម៌វិជ្ជាជីវៈ ត្រូវទទួលរងទណ្ឌកម្មខាងវិន័យ ដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត។

### មាត្រា១៧ .-

បែបបទនិងនីតិវិធីនៃការផាកពិន័យ ការបង់ប្រាក់ផាកពិន័យ ការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ផាកពិន័យ និងការចាត់ចែងប្រាក់ដែលបានមកពីការផាកពិន័យដូចដែលបានកំណត់នៅក្នុងអនុក្រឹត្យនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

## ផ្នែកទី២
## យន្តការត្រួតពិនិត្យការអនុវត្តកាតព្វកិច្ច

**មាត្រា១៨ .-**

ដើម្បីអនុវត្តកាតព្វកិច្ចគណនេយ្យនិងសវនកម្ម **ន.គ.ស.** មានសិទ្ធិអំណាចចុះត្រួតពិនិត្យដល់ទីកន្លែងរបស់សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ ប្រសិនបើសហគ្រាសនិងអង្គភាពមិនស្វែងរកប្រាក់ចំណេញនោះត្រូវបានចាត់ទុកថាមានហានិភ័យក្នុងករណីណាមួយដូចខាងក្រោម៖

១- សហគ្រាសឬអង្គភាពមិនស្វែងរកប្រាក់ចំណេញដែលមិនបានដាក់តម្កល់របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំនៅ **ន.គ.ស.**។

២- សហគ្រាសឬអង្គភាពមិនស្វែងរកប្រាក់ចំណេញដែលទទួលបានមតិពីសវនករឯករាជ្យថា «មិនត្រឹមត្រូវ» ឬ «បដិសេធ»។

៣- សហគ្រាសឬអង្គភាពមិនស្វែងរកប្រាក់ចំណេញដែលទទួលរងបណ្តឹងពាក់ព័ន្ធនឹងវិស័យនិងវិជ្ជាជីវៈគណនេយ្យនិង/ឬសវនកម្ម។

៤- សហគ្រាសឬអង្គភាពមិនស្វែងរកប្រាក់ចំណេញដែល **ន.គ.ស.** បានធ្វើការត្រួតពិនិត្យនិងវាយតម្លៃកម្រិតអនុលោមភាពរួច តែពុំបានកែលម្អកំហុសបន្ទាប់ពីបានរកឃើញ។

៥- ត្រូវចាត់ទុកថាមានហានិភ័យផ្សេងទៀត តាមការកំណត់របស់រាជរដ្ឋាភិបាលនិង/ឬរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

**មាត្រា១៩ .-**

បែបបទនិងនីតិវិធីនៃការត្រួតពិនិត្យការអនុវត្តកាតព្វកិច្ចគណនេយ្យនិងសវនកម្មរបស់សហគ្រាសនិងអង្គភាពមិនស្វែងរកប្រាក់ចំណេញ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

## ជំពូកទី៥
## ការមិនបង់ប្រាក់ផាកពិន័យនិងបណ្តឹងតវ៉ា

**មាត្រា២០ .-**

ក្នុងករណីបុគ្គលល្មើសមិនបង់ប្រាក់ផាកពិន័យក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ ទំហំប្រាក់ផាកពិន័យនេះត្រូវដំឡើងជាពីរដង។ ករណីខកខានបង់ប្រាក់ផាកពិន័យលើស៦០(ហុកសិប)ថ្ងៃ ទំហំប្រាក់ផាកពិន័យនេះត្រូវដំឡើងជាបីដង។ ករណីខកខានបង់ប្រាក់ផាកពិន័យលើស៩០(កៅសិប)ថ្ងៃ **ន.គ.ស.** ត្រូវចាត់វិធានការតាមផ្លូវច្បាប់ជាធរមាន។

រយៈពេល៣០(សាមសិប)ថ្ងៃ ៦០(ហុកសិប)ថ្ងៃ និង៩០(កៅសិប)ថ្ងៃ ខាងលើនេះ គិតចាប់ពីថ្ងៃបុគ្គលល្មើសបានទទួលលិខិតជូនដំណឹងផ្លូវការអំពីការបង់ប្រាក់ផាកពិន័យពី **ន.គ.ស.**។

ក្នុងករណីបុគ្គលល្មើសមិនព្រមបង់ប្រាក់ផាកពិន័យក្នុងរយៈពេល៩០(កៅសិប)ថ្ងៃ អគ្គនាយកនៃ **ន.គ.ស.** អាចអនុវត្តវិធានការមួយឬច្រើនដូចខាងក្រោម៖

- អញ្ជើញម្ចាស់សហគ្រាស ឬប្រធានអង្គភាពមិនស្វែងរកប្រាក់ចំណេញតាមគ្រប់មធ្យោបាយ ដោយទុករយៈពេល៣០(សាមសិប)ថ្ងៃ ឱ្យចូលខ្លួនមកបំភ្លឺ និង/ឬបំពេញកាតព្វកិច្ច

- ស្នើទៅក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីមានវិធានការស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។ ក្នុងករណីនេះ ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវផ្តល់កិច្ចសហការជាមួយ **ន.គ.ស.** ក្នុងការបំពេញមុខងារនិងការកិច្ចឱ្យមានប្រសិទ្ធភាពខ្ពស់
- ប្តឹងនិងបញ្ជូនសំណុំរឿងទៅអយ្យការអមសាលាដំបូងតាមនីតិវិធីជាធរមាន។

**មាត្រា២១ .-**

ប្រសិនបើបុគ្គលទទួលរងការផាកពិន័យមិនសុខចិត្តនឹងការសម្រេចផាកពិន័យ បុគ្គលនោះមានសិទ្ធិប្តឹងតវ៉ាទៅអគ្គនាយកនៃ **ន.គ.ស.** យ៉ាងយូរ៣០(សាមសិប)ថ្ងៃ ចាប់ពីថ្ងៃទទួលលិខិតជូនដំណឹង ឬបានទទួលដំណឹងជាក់លាក់អំពីការសម្រេច។

ក្នុងករណីដែលបុគ្គលទទួលរងការផាកពិន័យនៅតែមិនសុខចិត្តនឹងការសម្រេចលើការតវ៉ាដូចមានចែងក្នុងកថាខណ្ឌខាងលើ បុគ្គលនោះមានសិទ្ធិប្តឹងតវ៉ាទៅរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ ចាប់ពីថ្ងៃទទួលលិខិតជូនដំណឹងឬបានទទួលដំណឹងជាក់លាក់អំពីការសម្រេច។

ក្នុងករណីបុគ្គលទទួលរងការផាកពិន័យនៅតែមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ បុគ្គលនោះមានសិទ្ធិប្តឹងតវ៉ាទៅតុលាការមានសមត្ថកិច្ចតាមនីតិវិធីក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានសេចក្តីសម្រេច។

រយៈពេលប្តឹងតវ៉ាខាងលើមិនរាប់បញ្ចូលរយៈពេល ដូចមានកំណត់នៅក្នុងកថាខណ្ឌទី១នៃមាត្រា២០នៃអនុក្រឹត្យនេះឡើយ។

**មាត្រា២២ .-**

បែបបទនិងនីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយបណ្តឹងតវ៉ាចំពោះការសម្រេចផាកពិន័យត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា២៣ .-**

ការផាកពិន័យដែលកំណត់នៅក្នុងអនុក្រឹត្យនេះ ចាប់ផ្តើមអនុវត្តក្រោយរយៈពេល៦(ប្រាំមួយ)ខែ បន្ទាប់ពីកាលបរិច្ឆេទនៃអនុក្រឹត្យនេះ វៀរលែងតែបញ្ញត្តិនៃចំណុចទី៤ ចំណុចទី៥ ចំណុចទី៧នៃមាត្រា៦ ចំណុចទី៣ ចំណុចទី៤ ចំណុចទី៦នៃមាត្រា៧ ចំណុចទី៤ ចំណុចទី៥ ចំណុចទី៧នៃមាត្រា៨ និង ចំណុចទី៣ ចំណុចទី៤ ចំណុចទី៦នៃមាត្រា៩នៃអនុក្រឹត្យនេះ ដែលត្រូវអនុវត្តក្រោយរយៈពេល១(មួយ)ឆ្នាំ បន្ទាប់ពីកាលបរិច្ឆេទនៃអនុក្រឹត្យនេះ។

**មាត្រា២៤ .-**

អនុក្រឹត្យលេខ៧៩ អនក្រ.បក ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២០ ស្តីពីពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា២៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ៩កើត ខែជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រីសូមហត្ថលេខា
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ